ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខៈ ៤២៣៥ ប្រក

# ប្រកាស
## ស្តីពីការទទួលស្គាល់សមាសភាពប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ និងសមាជិកក្រុមប្រឹក្សាឃុំ នៃឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៨១ អនក្រ.បក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤
- យោងលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅឃុំ**ដាក់ដាំ** លេខកូដ **១១-០១២** នៃខេត្តមណ្ឌលគិរី( ទម្រង់បែបបទ១១១៨)របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧
- យោងសេចក្តីសម្រេចលេខ ៧២៥ គ.ជ.ប.ស.ស.រ ចុះថ្ងៃអង្គារ ៩ រោច ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី១២ ខែធ្នូ គ.ស ២០១៧ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្តីពីបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ បន្ទាប់ពីការបែងចែកអាសនៈដែលនៅទំនេរអនុលោមតាមមាត្រា២០ថ្មី និងមាត្រា២១ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

## សម្រេច

**ប្រការ ១.-**

ទទួលស្គាល់សមាសភាពជាប្រធានក្រុមប្រឹក្សាឃុំ និងសមាជិកក្រុមប្រឹក្សាឃុំ**ដាក់ដាំ** ស្រុកអូររាំង ខេត្ត**មណ្ឌលគិរី** ផ្អែកលើលទ្ធផល នៃការបែងចែកអាសនៈដែលនៅទំនេររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | លោក | ចាស ណា | ជាប្រធានក្រុមប្រឹក្សាឃុំ |
| ២- | លោក | ង៉ែត ប៉ា | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៣- | លោក | តាស់ លីម | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៤- | លោក | អ៊ើត ប៊ុន្នី | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៥- | លោក | យឹម ដាប៉ា | ជាសមាជិកក្រុមប្រឹក្សាឃុំ។ |

**ប្រការ ២.-**

ទទួលស្គាល់សមាសភាពជាមេឃុំ ជំទប់ទី១ និងជំទប់ទី២ នៃឃុំ**ដាក់ដាំ** ស្រុកអូររាំង ខេត្តមណ្ឌលគិរី ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | លោក | ចាស ណា | ជាមេឃុំ |
| ២- | លោក | ង៉ែត ប៉ា | ជាជំទប់ទី១ |
| ៣- | លោក | តាស់ លីម | ជាជំទប់ទី២។ |

**ប្រការ ៣.-**

ការអនុវត្តការងារ ប្រធានក្រុមប្រឹក្សាឃុំ សមាជិកក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ទី១ និងជំទប់ទី២ នៃឃុំ**ដាក់ដាំ** ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន។

**ប្រការ ៤.-**

ប្រកាសរបស់ក្រសួងមហាផ្ទៃលេខ ៣៣១៥ ប្រក ចុះថ្ងៃ២៧ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សាឃុំ ប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ទី១ ជំទប់ទី២ នៃឃុំដាក់ដាំ ស្រុកអូររាំង ខេត្តមណ្ឌលគិរី ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-**

ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៣កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**<u>កន្លែងទទួល</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អង្គភាពប្រឆាំងអំពើពុករលួយ

"ដើម្បីជូនជ្រាប"

- សាលាខេត្ត ស្រុក ឃុំ សាមី
- ដូចក្នុងប្រការ១

"ដើម្បីមុខការ"

- រាជកិច្ច
- ឯកសារ កាលប្បវត្តិ